# សុន្ទរកថា

## ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី

## ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

## ថ្លែងក្នុងឱកាសអបអរសាទរ ទិវាជាតិអាហារូបត្ថម្ភ លើកទី៣

## (៦ វិច្ឆិកា ២០១៤ - ៦ វិច្ឆិកា ២០១៦)

## ក្រោមប្រធានបទ "អនាម័យ និងអាហារូបត្ថម្ភល្អ ជួយឲ្យកុមារលូតលាស់ល្អ"

## សាលមហោស្រពចតុមុខ, ថ្ងៃទី ៤ ខែវិច្ឆិកា ឆ្នាំ២០១៦

- **ឯកឧត្តម លោកជំទាវ សមាជិក សមាជិកានៃរាជរដ្ឋាភិបាល**
- **ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំនៃអង្គការដៃគូអភិវឌ្ឍ**
- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ក្មួយៗនិស្សិត និងសមាជិក សមាជិកានៃអង្គពិធីទាំងមូលជាទីមេត្រី**

១. ថ្ងៃនេះ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ខ្ញុំមានសេចក្តីសោមនស្សរីករាយដោយបានចូលរួមប្រារព្ធខួប **ទិវាជាតិអាហារូបត្ថម្ភលើក ទី៣ , ៦ វិច្ឆិកា (២០១៤ - ២០១៦)** ក្រោមប្រធានបទ " **អនាម័យនិងអាហារូបត្ថម្ភល្អ ជួយឲ្យកុមារលូតលាស់ល្អ** " ក្នុងគោលបំណងអប់រំ និងលើកកម្ពស់ការយល់ដឹងជាសាធារណៈ ឲ្យបានទូលំទូលាយនៅទូទាំងប្រទេស អំពីសារៈសំខាន់នៃអាហារូបត្ថម្ភសម្រាប់កុមារ និងស្ត្រី ដល់ការអភិវឌ្ឍបញ្ញាស្មារតីកុមារ និងរូបរាងកាយរបស់ពួកគេ ដែលពួកគេគឺជាទំពាំងស្នងឫស្សីនៃប្រទេសជាតិ ក៏ដូចជាទំពាំងស្នងឫស្សីនៅក្នុងគ្រួសាររបស់យើងរាល់គ្នា។

២. ការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភ សម្រាប់ជនគ្រប់រូប ជាពិសេសស្ត្រីនិងកុមារ ដោយផ្តោតការយកចិត្តទុកដាក់លើកាត់បន្ថយអត្រាក្រិសក្រិនរបស់កុមារ តាមរយៈបង្កើនការយល់ដឹងអំពីសារៈសំខាន់ និងគុណប្រយោជន៍នៃការទំនាក់ទំនងគ្នារវាងវិស័យផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ វាគឺជាប្រធានបទថ្មីសម្រាប់ទិវាជាតិអាហារូបត្ថម្ភលើកទី៣ ក្នុងឆ្នាំនេះ ដោយយើងខិតខំអប់រំ សំដៅធ្វើឲ្យបងប្អូនប្រជាពលរដ្ឋគ្រប់រូប ពិសេសអាណាព្យាបាលក្មេង និងស្ត្រីជាមាតាឲ្យមានការផ្លាស់ប្តូរឥរិយាបថជាវិជ្ជមានក្នុងការប្រើប្រាស់ទឹកមានសុវត្ថិភាពសម្រាប់បរិភោគ ប្រើប្រាស់បង្គន់អនាម័យក្នុងគ្រួសារ និងការលាងសម្អាតដៃជានិច្ចជាមួយនឹងសាប៊ូ ដែលការអនុវត្តទាំងអស់នេះនឹងនាំឲ្យបញ្ហាកង្វះអាហារូបត្ថម្ភកុមារ និងស្ត្រីថយចុះនិងលុបបំបាត់ជាបណ្តើរៗនៅក្នុងសហគមន៍របស់យើង។ ខ្ញុំសូមវាយតម្លៃខ្ពស់ និងថ្លែងអំណរគុណដល់គ្រប់

ភាគីពាក់ព័ន្ធទាំងអស់នៃបណ្តាក្រសួង-ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដែលបានចូលរួមគាំទ្រដល់រាជរដ្ឋាភិបាល ក្នុងយុទ្ធនាការលើកកម្ពស់អាហារូបត្ថម្ភនាថ្ងៃនេះ។

៣. កុមារដែលមានបញ្ហាកង្វះអាហារូបត្ថម្ភ វាមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការរងគ្រោះពីជំងឺឆ្លងផ្សេងៗ ជាពិសេសនៅពេលពួកគេមានបញ្ហាកង្វះមីក្រូសារជាតិ វានឹងធ្វើឲ្យប្រព័ន្ធការពាររាងកាយពួកគេចុះខ្សោយ និងឈានទៅប្រឈមមុខនឹងជំងឺនានា និងការស្លាប់ផងដែរ ក្នុងនោះក៏រួមនឹងអត្រាមរណភាពមាតា និងកំណើតទារកកើតមកមិនគ្រប់ទម្ងន់។ ទាំងអស់នេះសុទ្ធតែជាការប្រឈមរបស់កុមារដែលមានបញ្ហាកង្វះអាហារូបត្ថម្ភ និងការប្រឈមទៅនឹងភាពក្រីក្រក្នុងគ្រួសារ ដែលយើងទាំងអស់គ្នាត្រូវកាត់ផ្តាច់រង្វង់ខួបនៃបញ្ហាទាំងអស់នេះនៅក្នុងសង្គម។

៤. ទោះបីបញ្ហាកង្វះទឹកស្អាតប្រើប្រាស់ កង្វះអនាម័យ វាមានការពាក់ព័ន្ធគ្នានឹងបញ្ហាអាហារូបត្ថម្ភយ៉ាងណាក៏ដោយ ក៏ការបំបៅដោះកូនដោយទឹកដោះម្តាយសុទ្ធ ក្នុងរយៈពេល ៦ខែដំបូងនៃជីវិតកុមារ និងការបំប៉នអាហារបន្ថែមដល់ទារក និងកុមារ គឺពិតជាមិនអាចខ្វះបានទេ ក្នុងវិធានការការពារនិងទប់ស្កាត់បញ្ហាកង្វះអាហារូបត្ថម្ភដល់កុមារ។ ការបំបៅទឹកដោះម្តាយសុទ្ធដល់ទារកក្នុងជីវិតដំបូង និងក្នុងរយៈពេល ៦ខែ គឺជាការអន្តរាគមន៍ដ៏មានប្រសិទ្ធភាពសម្រាប់ការពារពីការស្លាប់របស់កុមារ ដែលអ្នកស្រាវជ្រាវបានរកឃើញថាបានសង្គ្រោះជីវិតកុមារអាយុក្រោម ៥ឆ្នាំ បានរហូតដល់ទៅជាង ១លាននាក់នៅក្នុងពិភពលោក ហើយការបំប៉នអាហារបន្ថែមក៏អាចជួយកាត់បន្ថយបញ្ហាក្រិសក្រិនរបស់កុមារ បានដល់ទៅ ១៧% នៅក្នុងបណ្តាប្រទេសនានាដែលមានអត្រាបញ្ហាកង្វះអាហារូបត្ថម្ភខ្ពស់។ ដូចនេះ យុទ្ធសាស្ត្រនៃការធ្វើសមាហរណកម្មវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ទៅនឹងយុទ្ធសាស្ត្រប្រយុទ្ធនឹងបញ្ហាកង្វះអាហារូបត្ថម្ភ គឺពិតជាមានប្រសិទ្ធភាព ដោយយើងរួមបញ្ចូលជាមួយនឹងសកម្មភាពបំបៅទឹកដោះម្តាយដល់ទារក និងការបំប៉នអាហារបន្ថែមដល់ពួកគេ។

**ឯកឧត្តម លោកជំទាវ និងអង្គពិធីទាំងមូល** !

៥. ជាការពិតក្នុង ២ទសវត្សរ៍កន្លងមក តាមរយៈការដាក់ឲ្យអនុវត្តនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍សកលនៃអង្គការសហប្រជាជាតិ និងការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី បានដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្ររួម និងតាមវិស័យនានាជាច្រើន ព្រមទាំងបានវិនិយោគយ៉ាងច្រើនសន្ធឹកសន្ធាប់លើហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គម រួមមាន ផ្លូវថ្នល់ អគ្គិសនី ទឹក ប្រព័ន្ធធារាសាស្ត្រ សិក្សាអប់រំ សុខាភិបាល និងសេវាសង្គមផ្សេងៗទៀត ដើម្បីលើកស្ទួយកំណើនប្រកបដោយចីរភាព ជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងធានាកាត់បន្ថយភាពក្រីក្រឲ្យបានតាមគោលដៅជាង ១% ក្នុងមួយឆ្នាំ។ ជាមួយនឹងកិច្ចប្រឹងប្រែងនេះ កម្ពុជាសម្រេចបានកំណើន

សេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យម ៧,៧% ក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយ ដែលត្រូវបានធនាគារពិភពលោកចាត់បញ្ចូលជាប្រទេសក្នុងក្រុមឯកទគ្គករកំណើនទាំង ៨ នៅលើពិភពលោក។ ផលិតផលក្នុងស្រុកសរុបសម្រាប់ប្រជាជនម្នាក់បានកើនឡើងគួរជាទីមោទនៈ ពី ២៥៣ ដុល្លារអាមេរិក នៅឆ្នាំ១៩៩៨ ដល់ ១២២៥ ដុល្លារអាមេរិក នៅឆ្នាំ២០១៥ ។ លើមូលដ្ឋាននេះ អត្រាភាពក្រីក្រត្រូវបានកាត់បន្ថយពី ៥៣,២% នៅឆ្នាំ ២០០៤ មកត្រឹម ១៣,៥% នៅឆ្នាំ២០១៤ ដែលធ្វើឱ្យកម្ពុជាទទួលបានចំណាត់ថ្នាក់ជាប្រទេសជោគជ័យបំផុតទី៤ លើពិភពលោក ក្នុងការកាត់បន្ថយភាពក្រីក្រដោយសម្រេចបានគោលដៅអភិវឌ្ឍសហស្សវត្សរ៍ ក្នុងការកាត់បន្ថយអត្រាភាពក្រីក្រមុនកាលបរិច្ឆេទកំណត់នាចុងឆ្នាំ២០១៥ ទន្ទឹមនឹងការសម្រេចបានគោលដៅចំនួនបួនទៀត ដូចជាការកាត់បន្ថយអត្រាមរណភាពរបស់កុមារ និងការលើកកម្ពស់សុខភាពមាតា ជាដើម។

៦. លទ្ធផលដែលរាជរដ្ឋាភិបាលកម្ពុជាទទួលបានខាងលើនេះ ពិតជាមិនអាចកាត់ផ្តាច់បានពីការជួយជ្រោមជ្រែងដ៏សប្បុរស ពីសំណាក់ដៃគូអភិវឌ្ឍន៍ទាំងឡាយនោះឡើយ ដែលបានជួយឧបត្ថម្ភគាំទ្រយ៉ាងច្រើនដល់កម្ពុជា ក្នុងការវិនិយោគទាំងសេដ្ឋកិច្ច-សង្គម ពិសេសគឺទៅលើការកសាងសមត្ថភាពស្ថាប័ន និងធនធានមនុស្សនៅគ្រប់កម្រិត។ ជាក់ស្តែង ថ្ងៃនេះយើងរួមគ្នាប្រារព្ធទិវាជាតិអាហារូបត្ថម្ភ លើកទីពីរ ក្រោមប្រធានបទ “ **អនាម័យនិងអាហារូបត្ថម្ភល្អ ជួយឲ្យកុមារលូតលាស់ល្អ** ” សំដៅធ្វើយ៉ាងណាឱ្យបញ្ហាកង្វះអាហារូបត្ថម្ភកុមារ ត្រូវបានលុបបំបាត់ ពិសេសបញ្ហាកុមារក្រិសក្រិន ដែលជាជំងឺកង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃធ្ងន់ធ្ងរ និងនាំឱ្យទៅជាវិបត្តិប៉ះពាល់ដល់ការអភិវឌ្ឍសង្គម នៅពេលពួកគេធំឡើង។ លើកកម្ពស់អាហារូបត្ថម្ភ វាមិនមែនជាតួនាទីដាច់មុខរបស់ក្រសួង ស្ថាប័នណាមួយទេ តែវាគឺជាបញ្ហាអន្តរវិស័យដែលត្រូវធ្វើការរួមគ្នាក្នុងការលើកកម្ពស់អាហារូបត្ថម្ភ ក្នុងនោះមានទាំងវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ វិស័យកសិកម្ម វិស័យអប់រំ វិស័យសុខាភិបាល វិស័យព័ត៌មាន និងការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ ផងដែរ។

៧. ស្ថានភាពកុមារក្រិសក្រិននៅកម្ពុជា មានកម្រិតមួយខ្ពស់ដែលរាជរដ្ឋាភិបាល បានចាត់ជាអាទិភាពខ្ពស់ក្នុងការធ្វើអន្តរាគមន៍ពហុវិស័យ ដើម្បីបង្ការការពារ និងទប់ស្កាត់។ ផ្អែកលើរបាយការណ៍អង្កេតសុខភាព និងប្រជាសាស្ត្រឆ្នាំ២០១៤ របស់ក្រសួងផែនការ កម្ពុជាមានកុមារក្រិសក្រិន ៣២%, កុមារមានស្ថានភាពស្គមស្គាំងក្នុងកម្រិត ៩.៤% ។ ការវាយតំលៃផ្នែកសេដ្ឋកិច្ចមួយ ក៏បានធ្វើការប៉ាន់ប្រមាណផងដែរថា ការចំណាយលើកង្វះអាហារូបត្ថម្ភ អាចមានតម្លៃពី ២៥០ លានដុល្លារ ទៅ ៤០០ លានដុល្លារ ក្នុងមួយឆ្នាំ ប្រសិនបើគ្មានការចាត់វិធានការការពារជាមុន ដើម្បីទប់ស្កាត់បញ្ហាកង្វះអាហារូបត្ថម្ភនៅកម្ពុជានោះទេ។ ដូចនេះ ការវិនិយោគដើម្បីកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភ គឺជារបៀបវារៈដ៏សំខាន់មួយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការរួមសហការជាមួយនឹងដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីលើកកម្ពស់អាហារូបត្ថម្ភនៅកម្ពុជា ពិសេសកុមារពីអាយុ ០ ខែ ដល់ ៥ ឆ្នាំ ដោយយើងទាំងអស់គ្នាដឹងហើយថា កុមារ

គឺជាមូលធនមនុស្សមិនអាចខ្វះបានសម្រាប់បន្តវេនក្នុងការអភិវឌ្ឍប្រទេសជាតិ និងមាតុភូមិយើងនាពេលអនាគត។

៨. ម្យ៉ាងវិញទៀត ការស្រាវជ្រាវរបស់បណ្ដាអ្នកជំនាញនានាក៏បានបង្ហាញថា ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ វាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើស្ថានភាពអាហារូបត្ថម្ភ ក្នុងនោះកុមារប្រមាណ ៥០% ដែលមានបញ្ហាកង្វះអាហារូបត្ថម្ភ គឺបណ្ដាលមកពីបញ្ហាកង្វះទឹកស្អាតសម្រាប់ផឹក មិនប្រើប្រាស់បង្គន់អនាម័យ និងមិនមានទម្លាប់លាងសម្អាតដៃជាមួយនឹងសាប៊ូ។ កត្តាទាំងអស់នេះ គឺជាដើមចមដែលធ្វើឲ្យមានការកើនឡើងបញ្ហាកង្វះអាហារូបត្ថម្ភ ជាពិសេសក្នុងអំឡុងពេល ១០០០ថ្ងៃដំបូងនៃជីវិតកុមារដែលពួកគេកំពុងតែលូតលាស់បញ្ញាស្មារតី និងរូបរាងកាយ ដែលធ្វើឲ្យពួកគេរងគ្រោះបញ្ហាក្រិសក្រិន ស្គមស្គាំង និងធ្ងន់ធ្ងរជាងនេះទៀតអាចបណ្ដាលឲ្យកុមារស្លាប់បាន។ អាស្រ័យហេតុនេះ ការធ្វើអន្តរកម្មរវាងវិស័យផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងអាហារូបត្ថម្ភ គឺជាការចាំបាច់ដើម្បីកែលម្អស្ថានភាពអាហារូបត្ថម្ភឲ្យមានប្រសិទ្ធភាព ដូចប្រសាសន៍ដ៏ថ្លៃថ្លារបស់សម្ដេចតេជោនាយករដ្ឋមន្ត្រី នៅក្នុងសារលិខិតអបអរសាទរទិវាជាតិអាហារូបត្ថម្ភជាតិលើកទី៣ នាថ្ងៃនេះ។

៩. មុននឹងបញ្ចប់សុន្ទរកថានេះ ខ្ញុំសូមអំពាវនាវឲ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់បន្តកិច្ចសហការជាមួយគ្នាតទៅទៀត ដើម្បីប្រយុទ្ធនឹងបញ្ហាកង្វះអាហារូបត្ថម្ភ គ្រប់ទម្រង់ដែលបានប៉ះពាល់លើកុមារ និងស្ត្រី។ ខ្ញុំសូមប្រសិទ្ធិពរជូនឯកឧត្តម លោកជំទាវ តំណាងអង្គការជាតិ អន្តរជាតិ អស់លោក លោកស្រី អ្នកនាង កញ្ញាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិទាំងអស់ សូមទទួលបាននូវពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

***សូមអរគុណ !***